# ការពារអ្វីដែលត្រឹមត្រូវ

ដោយ អាសឺ តាន រដ្ឋ យូថាហ៍ ស. រ. អា.



**សួស្ដី ខ្ញុំឈ្មោះអ៊ីវ៉ាន !**
ខ្ញុំរស់នៅប្រទេស អៀរឡង់ ខ្ញុំចូលចិត្តលេងកីឡាមួយដែលហៅថាកីឡាវាយកូនបាល់ ។ វាជាកីឡាអៀរឡង់ដែលដូចជាកីឡាវាយកូនបាល់លើទឹកកកដែរ ។ មុខវិជ្ជាដែលខ្ញុំចូលចិត្តរៀននោះគឺគណិតវិទ្យា ។ ធ្វើជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជាពរជ័យមួយសម្រាប់ខ្ញុំ ។



**ការឈរយ៉ាងរឹងមាំនៅសាលារៀន**
*ក្មេងប្រុសម្នាក់ទើបចូលរៀននៅសាលាបានសម្លុតប្អូនស្រីរបស់ខ្ញុំ ។ ខ្ញុំបានចូលទៅឈរចំកណ្ដាលពួកគេ ហើយបានការពារប្អូនស្រីរបស់ខ្ញុំ ។ ខ្ញុំក៏គោរពតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃផងដែរ ។ សិស្សជាច្រើននៅសាលារៀនផឹកតែ និង កាហ្វេ ។ ពេលមាននរណាម្នាក់ឲ្យតែខ្ញុំផឹក ខ្ញុំនិយាយថា « ខ្ញុំអត់ផឹកទេ សូមអរគុណ » ។*



**អធិស្ឋានជាមួយមិត្តភក្ដិ**
*ខ្ញុំទៅរៀននៅសាលាកាតូលិក ។ ប្អូនស្រីរបស់ខ្ញុំ និង ខ្ញុំគឺជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយដែលរៀននៅទីនោះ ។ ពេលជីដូនរបស់ខ្ញុំឈឺ ខ្ញុំបានសុំគ្រូរបស់ខ្ញុំប្រសិនបើខ្ញុំអាចអធិស្ឋានសម្រាប់គាត់ ។ សិស្សទាំងអស់នៅក្នុងថ្នាក់ឱបដៃ ហើយ ឱនក្បាលចុះ ។ ខ្ញុំបានអធិស្ឋានឲ្យពីសិស្សក្នុងថ្នាក់ ។*

**យោបល់របស់អ៊ីវ៉ាន ដើម្បីឈរយ៉ាងរឹងមាំ**
វាតម្រូវឲ្យចិត្តក្លាហានដើម្បីរស់នៅតាមដំណឹងល្អ ។

- សូមកុំចុះចាញ់ឡើយ ។
- សូមស្ដាប់តាមព្រះវិញ្ញាណបរិសុទ្ធ ។ ទ្រង់នឹងដឹកនាំអ្នក ។
- សូមចាំថា ការជួយនរណាម្នាក់ឲ្យទទួលដំណឹងល្អ នឹងធ្វើឲ្យជីវិតរបស់ពួកគេកាន់តែរីករាយ ។

**បងប្រុសច្បងដ៏ល្អបំផុត**
*ខ្ញុំដាក់គោលដៅបន្តធ្វើអ្វីដែលត្រឹមត្រូវ ។ ខ្ញុំជួយឪពុកម្ដាយខ្ញុំមើលថែប្អូនស្រីរបស់ខ្ញុំ ។ នៅពេលប្អូនស្រីរបស់ខ្ញុំភ័យខ្លាច នោះខ្ញុំលេងជាមួយពួកគេរហូតដល់ពួកគេភ្លេចភាពខ្លាចនោះ ។ មានគ្រាមួយនោះ នៅពេលឪពុកម្ដាយខ្ញុំមិននៅផ្ទះ ខ្ញុំបាននិទានរឿងឲ្យប្អូនស្រីខ្ញុំស្ដាប់រហូតដល់នាងដេកលក់ ។*

**ធ្វើជាគំរូ**
*មិត្តភក្ដិរបស់ខ្ញុំនៅសាលារៀនឃើញថាខ្ញុំមានចិត្តរីករាយ ។ ខ្ញុំធ្វើជាគំរូល្អដោយមិនប្រើពាក្យជេរ ឬ យកព្រះនាមរបស់ព្រះអម្ចាស់ជាអសាឥតការឡើយ ។ ខ្ញុំអាចធ្វើជាគំរូដល់គ្រួសារខ្ញុំផងដែរ ។*

## សូមផ្ញើស្នាមបាតជើងរបស់អ្នកមកកាន់យើង !
តើអ្នកឈរយ៉ាងរឹងមាំក្នុងការធ្វើតាមព្រះយេស៊ូវយ៉ាងដូចម្ដេច ? សូមគូសស្នាមបាតជើងរបស់អ្នក ហើយផ្ញើរឿង និង រូបថតរបស់អ្នកមកកាន់យើងខ្ញុំ ព្រមជាមួយនឹងការអនុញ្ញាតពីឪពុកម្ដាយរបស់អ្នកមកផងដែរ ។ សូមផ្ញើវាមកតាមរយៈគេហទំព័រ liahona.lds.org ( ចុច « Submit an Article » ) ឬ អ៊ីម៉ែល liahona@ldschurch.org ។

